មជ្ឈមណ្ឌលឯកសារកម្ពុជា

# របាយការណ៍
# នៃការចុះស្រាវជ្រាវទីតាំងប្រល័យពូជសាសន៍
# នៅខេត្តកំពង់ចាមពីថ្ងៃទី២៤-២៨ ខែឧសភា ឆ្នាំ២០០០

---

ដោយ ផេង ពង្សរ៉ាស៊ី

កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០០ ក្រុមផែនទីរូមមានឈ្មោះ ស៊ីន ឃិន, អ៊ូច សំអឿន, ជួង សុភារិទ្ធ និងផេង ពង្សរ៉ាស៊ី បានចាកចេញពីទីក្រុងភ្នំពេញនៅម៉ោង ៧ ព្រឹកតាមរថយន្តមួយគ្រឿងឆ្ពោះទៅកាន់ខេត្តកំពង់ចាមដើម្បីសិក្សាស្រាវជ្រាវបន្តពីឆ្នាំ១៩៩៩ ទៅលើស្រុកចំនួនបី ។ ស្រុកទាំងបីនោះគឺ ស្រុកចំការលើ, ស្រុកព្រៃឈរ និង ស្រុកបាធាយ ។

យោងតាមរបាយការណ៍រណ្តៅផែនទីពីឆ្នាំ ១៩៩៥-៩៩ ស្រុកទាំងបីនេះនៅមានទីតាំងមួយចំនួនដែលក្រុមយើងមិនបានទៅដល់ ហើយលើកយកមកធ្វើការសិក្សាស្រាវជ្រាវនាពេលនេះ (ឆ្នាំ២០០០)វិញ ។

ក្រោយពីបានទៅដល់សាលាខេត្តកំពង់ចាមនៅម៉ោង ៩:០៥ និងក្រោយពីបាទទួលលិខិតអនុញ្ញាតិពីខុទ្ទល័យខេត្តរួចមក ក្រុមស្រាវជ្រាវបានបន្តដំណើរឆ្ពោះទៅកាន់ស្រុកចំការលើក្នុងថ្ងៃដដែលនោះ (២៤ ខែឧសភា ឆ្នាំ២០០០) ។ ក្នុងដំណើរវិលត្រឡប់ពីទីរួមខេត្តកំពង់ចាមឆ្ពោះមកទិសខាងលិច (តាមផ្លូវជាតិលេខ៦មកភ្នំពេញ) ប្រហែលជាង ៣០គីឡូម៉ែត្រ យើងក៏បានបត់មកទិសខាងជើងតាមផ្លូវជាតិលេខ៧១ ចំនួន ៣១ គីឡូម៉ែត្រទៀតទើបទៅដល់សាលាស្រុកចំការលើ ។

## ស្រុកចំការលើ

១- ទីតាំងសម្លាប់ និង មន្ទីរសន្តិសុខនៅចំការស្វាយចន្ទី (ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០០)

ចំការស្វាយចន្ទី ស្ថិតនៅក្នុងភូមិវាំរីលិច ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ។ ចំការនេះស្ថិតនៅប្រហែល២០០ម៉ែត្រខាងលិចសាលារៀនស្វាយទាប ហើយមានទំហំដីប្អូនហិកតា ។ របងព័ទ្ធជុំវិញចំការសុទ្ធតែព្រៃឫស្សីក្រាស់ៗពិបាកនឹងចូលដល់ ។ បច្ចុប្បន្នចំការនេះ ត្រូវបានបែងចែកទៅឲ្យមនុស្សបីនាក់ ។ អ្នកទាំងបីនោះឈ្មោះតា ឆេង ចំនួនពីរហិកតា, តាចេង ចំនួនមួយហិកតា និង តាឈិន ចំនួនមួយហិកតា ។ ដីចំការនេះ

ត្រូវបានពួកគាត់ទាំងបីដាំដំណាំផ្សេងៗពីគ្នា ដូចជាល្ហុង, ស្វាយចន្ទី, ស្វាយថៃ, មាក់ប្រេង, ល្ហុង.........។ល។ ព្រមទាំងមានកូនខ្ទមមួយសំរាប់យាមដំណាំទាំងនោះទៀតផង។

ប្រជាជនស្ទើរតែគ្រប់គ្រួសារ គ្រប់ភូមិសុទ្ធតែបានដឹង និងឮថា ចំការស្វាយចន្ទីជាកន្លែងសម្លាប់មនុស្សច្រើនជាងគេនៅស្រុកចំការលើ។ យោងតាមសំដីរបស់លោកប្រធានឃុំស្វាយទាបឈ្មោះ គីង យ៉ាត អាយុ៥១ឆ្នាំ ថាចំការស្វាយចន្ទីនេះ កាលពីឆ្នាំ១៩៧៥រហូតមកដល់ពាក់កណ្តាលឆ្នាំ១៩៧៨ ជាមន្ទីរសន្តិសុខប្រចាំឃុំស្វាយទាប ហើយចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៨រហូតដល់ជិតបែកឆ្នាំ១៩៧៩ កន្លែងនេះ (ចំការស្វាយចន្ទី) ក្លាយជាកន្លែងសម្លាប់មនុស្សយ៉ាងសាហាវបំផុត។ គីង យ៉ាត បន្តថា វិធីសម្លាប់មនុស្សរបស់ខ្មែរក្រហមគឺហៅប្រជាជន ជាពិសេសប្រជាជនថ្មី (១៧មេសា) ឲ្យមកប្រជុំ ដោយប្រាប់ថាប្រជុំត្រៀមផ្លាស់ប្តូរទីលំនៅពីភូមិមួយទៅភូមិមួយទៀត។ កិច្ចប្រជុំធ្វើឡើងនៅម៉ោង ៤ ល្ងាចភ្លឺ។ ប្រជាជនដែលត្រូវចូលរួមប្រជុំមិនត្រូវបានពួកខ្មែរក្រហមអនុញ្ញាតិឲ្យយកឥវ៉ាន់មកជាប់ជាមួយខ្លួនច្រើនឡើយ។ យ៉ាត បន្ថែមថា ក្រោយពីប្រជុំចប់ និងក្រោយពីហៅឈ្មោះឲ្យឡើងជិះរទេះគោរួច ប្រជាជនទាំងនោះត្រូវបានពួកខ្មែរក្រហមដឹកយកមកសម្លាប់ចោលទាំងអស់នៅចំការស្វាយចន្ទីនេះ។ តាមសំដី យ៉ាត ថាប្រហែលជាខែ៧-៨ ឆ្នាំ១៩៧៨ ព្រឹត្តិការណ៍នោះបានកើតឡើង។ យ៉ាត បាននិយាយបន្តថា ក្នុងបរិវេណចំការស្វាយចន្ទីមានរណ្តៅសាកសពច្រើន ប៉ុន្តែរណ្តៅដែលធំៗមាន ៖

-រណ្តៅបួនជ្រុងទ្រវែង ចំនួន៣រណ្តៅ ដែលមានទំហំទទឹង២ម៉ែត្រ និងបណ្តោយ៣០ម៉ែត្រ (ប្រភពមិនបានបញ្ជាក់ពីជំរៅ)។

-រណ្តៅគ្រាប់បែក ចំនួន២រណ្តៅ ដែលមានទំហំផ្ចិតវិជ្ជ១០ម៉ែត្រ ដែលទំលាក់ដោយទាហានលន់ណុលពីឆ្នាំ១៩៧២-៧៣។

-រណ្តៅជាលក្ខណៈប៉ុសយោធាហាន (លេណដ្ឋាន) វែងៗ ដែលមានទំហំទទឹង ២ ម៉ែត្រ និង បណ្តោយ ១០០ម៉ែត្រ ជំរៅ១,៥ម៉ែត្រ។

ចំពោះសាកសពជនរងគ្រោះដែលបានស្លាប់នៅចំការស្វាយចន្ទី យ៉ាត បានប្រាប់ថាមានចំនួនប្រហែលពី ៥០០០-៧០០០នាក់ (គិតពីខែ៧ ឆ្នាំ១៩៧៨ ដល់ដើមខែមករា ឆ្នាំ១៩៧៩)។ សាកសពទាំងនោះ ត្រូវបានប្រជាជនរស់នៅភូមិក្បែរទីតាំងស្វាយចន្ទីគាស់រើកកាយឆ្អឹងឡើងលើមាត់រណ្តៅដើម្បីរកមាស និងគ្រឿងអលង្ការផ្សេងៗ ហើយក្រោយមកឆ្អឹងទាំងនោះប្រហែលមួយភាគដប់នៃឆ្អឹង ក៏ត្រូវបានថែរក្សាទុកនៅលើមាត់រណ្តៅធំនោះ ដោយមានប្រជាពលរដ្ឋសាងសង់ជាកូនខ្ទមមួយដាក់ដើម្បីការពារថ្ងៃនិងភ្លៀង។ រហូតដល់បច្ចុប្បន្នអដ្ឋិធាតុទាំងនោះបានបាត់បង់អស់ទៅហើយ។

បន្ទាប់ពីបញ្ចប់កិច្ចសម្ភាសន៍រវាងក្រុមដែនទីជាមួយលោកមេឃុំ គីង យ៉ាតមក យើងក៏បានទៅពិនិត្យដល់ទីតាំងចំការស្វាយចន្ទីផ្ទាល់តែម្តង ដោយមានការជូនដំណើរពីមេឃុំរូបនោះដែរ ។

ទៅដល់ទីតាំងសម្លាប់ និងមន្ទីរសន្តិសុខចំការស្វាយចន្ទីនៅម៉ោង ២:៤៥នាទី រសៀល ។ នៅទីនោះក្រុមយើងបានជួបជាមយយអ្នកដែលបានដឹងរឿងរ៉ាវពីចំការស្វាយចន្ទីច្បាស់ចំនួនពីររូបទៀតគឺឈ្មោះ ឡុង សុខខៃ និង លី ឃិន ។

ឡុង សុខខៃ បានផ្តល់បទសម្ភាសន៍ដល់ក្រុមដែនទីអំពីទីតាំងសម្លាប់ និងទីតាំងមន្ទីរសន្តិសុខចំការស្វាយចន្ទីថា គាត់មានអាយុ៥១ឆ្នាំ មានស្រុកកំណើតនៅឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម ។ សម័យប៉ុលពតរស់នៅភូមិវារីលិច ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ហើយបច្ចុប្បន្នរស់នៅភូមិវារីកើត ឃុំស្វាយទាប ។ សុខខៃ ជាជនរងគ្រោះម្នាក់ដែលបានទៅចូលរួមប្រជុំជាមួយប្រជាជនផ្សេងៗដើម្បីផ្លាស់ប្តូរទីលំនៅ តាមដែលប្រធានកង-ប្រធានក្រុមប្រាប់ ប៉ុន្តែដោយគាត់គ្មានឈ្មោះត្រូវផ្លាស់ប្តូរទីលំនៅ ទើបគាត់ត្រូវរួចខ្លួនរហូតដល់សព្វថ្ងៃ ។ សុខខៃ បានប្រាប់ថានៅខែជេស្រ-អាសាឍ (ខែ៦-៧)ក្នុងឆ្នាំ១៩៧៨ ក្នុងថ្ងៃមួយនោះគាត់ត្រូវបានប្រធានកងហាមមិនឲ្យគាត់ចេញរទេះទៅដឹកអុសឡើយ(សុខខៃជាអ្នកបររទេះដឹកអុស) គឺឲ្យនៅចូលរួមប្រជុំសិននៅម៉ោង៩:៣០នាទីព្រឹក ។ លុះប្រជុំត្រូវបញ្ចប់ គាត់(សុខខៃ) ត្រូវបានអនុញ្ញាតិឲ្យទៅដឹកអុសដូចរាល់ដងនៅឃុំចំការអណ្តូង ស្រុកចំការលើ ។ នៅពេលដែលគាត់រៀបនឹងចេញរទេះ ស្រាប់តែប្រទះឃើញប្រជាជនមកពីភូមិផ្សេងៗ ក្នុងឃុំស្វាយទាប ដូចជាភូមិចិន, ភូមិត្រពាំងបេង, ភូមិព្រីក ដើរខ្លះ ជិះរទេះគោខ្លះ សំដៅមកកាន់ចំការស្វាយចន្ទី ។ សុខខៃ ប្រាប់ថាគាត់ញមានអារម្មណ៍ចំឡែកដែរ ប៉ុន្តែដោយមានភារកិច្ចត្រូវធ្វើ គាត់ក៏ចេញរទេះទៅ ។ ពេលត្រលប់មកវិញ សុខខៃ បានឮសូរសំលេងចាក់មេក្រូនៅចំការស្វាយចន្ទី ។ ក្រោយមកទើបដឹងថាជាសំលេងដែលចាក់បំភាន់ប្រជាជននៅក្បែរទីតាំង មិនឲ្យឮការសម្លាប់របស់ពួកខ្មែរក្រហម ។

សុខខៃ បន្តថាមុនមួយថ្ងៃនៃការសម្លាប់ ក៏ដូចជាមុនមួយថ្ងៃនៃការប្រជុំ គាត់ត្រូវបានពួកប្រធានកង (មិនស្គាល់ឈ្មោះ) ឲ្យមកយាមនៅទិសខាងលិចចំការស្វាយចន្ទី (ជាប់របងគុម្ពឫស្សី) ។ ក្នុងយប់នោះ សុខខៃ បានឮសូរសំលេងកាប់ដីពេញមួយយប់ ។ សុខខៃ បញ្ជាក់ថាអ្នកដែលមកកាន់ដីនោះ គឺជាប្រជាជនដែលជាប់និន្នាការ និងជនជាតិយួន ហើយក្រោយពីកាប់រួចក៏ត្រូវពួកខ្មែរក្រហមសម្លាប់ចោលតែម្តងទៅ ។

ចំពោះការសម្លាប់វិញ សុខខៃនិយាយថា ពួកខ្មែរក្រហមបានបែងចែកជាបីដំណាក់កាលគឺៈ

-ដំណាក់កាលទី១ៈ យកជនជាតិយួនមកសម្លាប់មុន (អ្នកជាប់ខ្សែយួន) ព្រោះពួកខ្មែរក្រហមគិតថាជាការសងសឹកមួយចំពោះការវាយបកពីយួនមកលើខ្មែរក្រហមនៅដើមឆ្នាំ១៩៧៨ ។

-ដំណាក់កាលទី២៖ យកប្រជាជន (ពិសេសប្រុសៗ) ដែលមានមាឌធំៗ មាំ មកសម្លាប់ដោយបញ្ឆោតថាឲ្យមកជួយរៀបចំផ្ទះ ។ ក្រោយមកក៏យកទាំងគ្រួសារ (ប្រពន្ធ-កូន) មកសម្លាប់តាមក្រោយទៀត ។

-ដំណាក់កាលទី៣៖ យកប្រជាជនគ្រប់ភូមិក្នុងឃុំស្វាយទាបមកសម្លាប់រួម ។

ឯរណ្ដៅសាកសពនិងចំនួនសាកសព សុខខៃ បានប្រាប់ដូចដែលលោកមេឃុំ គឹង យ៉ាត បានប្រាប់ដែរ ។ ប៉ុន្តែ សុខខៃ បន្ថែមថារណ្ដៅធំៗចំនួនបី ទំហំទទឹង៧ម៉ែត្រ និង បណ្ដោយ៣០ម៉ែត្រនៃរណ្ដៅមួយៗ ជីកតាមបណ្ដោយគុម្ពឫស្សី ជ្រុងខាងលិចបរិវេណចំការស្វាយចន្ទី ដោយទុកចន្លោះពីរណ្ដៅមួយទៅរណ្ដៅមួយទៀតប្រហែល ៥ម៉ែត្រ ។ ជនរងគ្រោះដែលបានស្លាប់ក្នុងរណ្ដៅនោះមានប្រមាណពី ៥០០០-៧០០០នាក់ ។ ចំណែករណ្ដៅគ្រាប់បែកមានបី ដែលមួយៗមានអង្កត់ផ្ចិតប្រហែល៥-៦ម៉ែត្រ ជំរៅ២ម៉ែត្រ (តាមសំដីគឹង យ៉ាត ថាមានអង្កត់ផ្ចិត១០ម៉ែត្រ និង ជំរៅ១,៥ម៉ែត្រ) ។ មានមនុស្សស្លាប់ជាង២០០នាក់ ។ មនុស្សដែលបានស្លាប់នៅក្នុងរណ្ដៅគ្រាប់បែក ជាកងចល័តរបស់ខ្មែរក្រហម ។ ពួកកងចល័តទាំងនោះ ត្រូវបានពួកខ្មែរក្រហមយកមកសម្លាប់មុនការសម្លាប់រួមទាំង១៣ភូមិ ក្នុងឃុំស្វាយទាប ។ រណ្ដៅគ្រាប់បែកនេះស្ថិតនៅទិសខាងជើងនៃបរិវេណចំការស្វាយចន្ទី (ឆ្ងាយពីរណ្ដៅធំប្រហែលជាង១០០ម៉ែត្រ) ។ នៅមានរណ្ដៅតូចៗជាច្រើនទៀត ដែលសុខខៃមិនអាចធ្វើការប៉ាន់ស្មានបាន ព្រោះរណ្ដៅតូចៗនោះ ត្រូវបានជីក និង សម្លាប់ប្រជាជនដាក់ស្ទើរតែរាល់ថ្ងៃ ។ សម្លាប់ម្ដងពី២-៥នាក់ក្នុងមួយរណ្ដៅតូចនេះ ។ សុខខៃ ក៏បានធ្វើការប៉ាន់ស្មានរួមនូវចំនួនសាកសពដែលបានស្លាប់ក្នុងចំការស្វាយចន្ទីថាមានចំនួន **ជាងមួយម៉ឺននាក់** ។

ក៏មានការបញ្ជាក់ពី សុខខៃ ដែរថាវិធីសម្លាប់របស់ខ្មែរក្រហមគឺបណ្ដើរមនុស្សមកសម្លាប់មានចងស្លាបសេក គ្មានចងមុខ រួចឲ្យលុតជង្គង់នៅមាត់រណ្ដៅជាជួរៗ បន្ទាប់មកក៏ចាប់ផ្ដើមវាយសម្លាប់ ដោយពួកខ្មែរក្រហមប្រើដែកបំពង់ទីបសំរាប់វាយសម្លាប់ ។ ដែកនេះមានទំហំធំជាងមេដើងបន្តិច និង គល់ឫស្សី ។

ការសម្លាប់មនុស្សរបស់ខ្មែរក្រហម បានប្រព្រឹត្តទៅយ៉ាងសាហាវបំផុត ដូច សុខខៃ បានរៀបរាប់ថាការសម្លាប់ទៅលើកងចល័តជាង ២០០ នាក់តែក្នុងរយៈពេលមួយថ្ងៃ ហើយសម្លាប់ប្រជាជនទាំង១៣ភូមិ ក្នុងឃុំស្វាយទាប ក៏ក្នុងរយៈពេលមួយថ្ងៃដែរ (អស់ពី៥០០០-៧០០០នាក់) ។ មនុស្សដែលត្រូវបានសម្លាប់នៅទីនោះ (ស្វាយចន្ទី) មិនត្រូវបានជាប់មន្ទីរសន្តិសុខណាទេ គឺសុទ្ធតែជាប្រជាជនស្លូតត្រង់ ហើយត្រូវមកសម្លាប់ចោលតែម្ដង ។

សាកសពទាំងនោះ មិនត្រូវបានលុបដីជិតទាំងស្រុងទេ ។ ក្រោយថ្ងៃរំដោះ១៩៧៩ មានប្រជាជនជាច្រើនបាននាំគ្នាជីកកកាយក្នុងរណ្ដៅសាកសពដើម្បីរកមាស-ពេជ្រផ្សេងៗ ដែលជាហេតុធ្វើឲ្យឆ្អឹងមួយចំនួនត្រូវ

របុាត់របុាយនៅលើមាត់រណ្តៅ ។ ក្រោយមកទៀតបានរដ្ឋអំណាចឃុំស្វាយទាបប្រមូលដាក់មួយកន្លែងនៅលើមាត់រណ្តៅដោយបានធ្វើជាស្តូបតូចមួយសំរាប់ការពារខ្យល់ ក្តៅ ភ្លៀងអោយអដ្ឋិធាតុទាំងនោះ ។ ប៉ុន្តែក្រោយមកអដ្ឋិធាតុនោះក៏បានយកទៅតំកល់នៅក្នុងវត្តស្វាយទាបជាច្រើនលើកច្រើនសារកន្លងមក អដ្ឋិធាតុទាំងនោះត្រូវបានបាត់បង់អស់ដោយពុំដឹងអំពីមូលហេតុច្បាស់លាស់ ។ សូមបញ្ជាក់ផងដែរ អដ្ឋិធាតុដែលបានប្រមូលនោះមិនបាន១ ៗ១០នៃឆ្អឹងទាំងអស់ក្នុងចំការស្វាយចន្ទីទេ ។

សុខខៃធ្លាប់បានជួបឈុន ឡាម្តងនៅចុងឆ្នាំ១៩៧៧នៅពេលដែលគាត់(សុខខៃ)កំពុងបរទេះដឹកអូស ។ ឈុន ឡាបានបញ្ជាអោយកងការពារឃាត់រទេះរបស់សុខខៃអោយឈប់រួចឈុន ឡាក៏បានចុះទៅប្រាប់សុខខៃថា «ពេលត្រលប់ទៅដល់ផ្ទះ សូមយកទឹកនោមរបស់ខ្លួនឯងមកលាបកគោដើម្បីកុំអោយហើមកតទៅទៀត» ។ ព្រោះពេលនោះគោរបស់សុខខៃហើមកខ្លាំង ។ ឈុន ឡាជាប្រធានភូមិភាគ៣០៤ ឬភូមិភាគកណ្តាលមានប្រពន្ធឈ្មោះ សឿងជាគណៈស្រុកចំការលើ ។

បន្ទាប់ពីបានជួបឡុង សុខខៃរួចនៅថ្ងៃដដែល(២៤-៥-២០០០) ក្រុមយើងក៏បានទៅជួបជាមួយលោកអ៊ំម្នាក់ទៀតឈ្មោះ លី ឃិន ។

ឃិន មានអាយុ៥៦ឆ្នាំ ស្រុកកំណើតនៅភូមិស្វាយព្រៃ ឃុំសំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ បច្ចុប្បន្ន ឃិន រស់នៅភូមិវាំវីលិច ឃុំស្វាយទាប ស្រុកចំការលើ ។ អ្វីដែលលី ឃិនបាននិយាយមិនខុសពីអ្វីដែល ឡុង សុខខៃបាននិយាយទេ ប៉ុន្តែឃិន បានបន្ថែមថាពីឆ្នាំ១៩៧៥ ដល់ ១៩៧៨ មន្ទីរសន្តិសុខចំការស្វាយចន្ទីបានយកមនុស្សមកឃុំឃាំងច្រើនតែប្រភេទអ្នកជាប់និន្នាការនយោបាយតាំងពីជំនាន់សីហនុ, លន់ណុល អ្នកខ្ជិលច្រអូសមិនមកធ្វើការ អ្នកខុសសីលធម៌...ៗល ។ អ្នកទោសទាំងនោះត្រូវបានសំលាប់ចោលទាំងអស់នៅទីនោះ (ចំការស្វាយចន្ទី) បន្ទាប់ពីបានប្រែក្លាយពីមន្ទីសន្តិសុខទៅជាកន្លែងសំលាប់ដ៏ធំរួចមក ។ លី ឃិនបន្តថាប្រជាជនទាំង១៣ភូមិក្នុងឃុំស្វាយទាប ត្រូវបានពួកខ្មែរក្រហមសម្លាប់តាំងពីព្រលឹមរហូតដល់ល្ងាច(៥០០០ទៅ៧០០០នាក់) ក្រោមរូបភាពស៊ីផឹកសប្បាយពីអ្នកសំលាប់ និងមានការចាក់មេក្រូយ៉ាងទ្រហឹងផងដែរ ។ ក្នុងចំការស្វាយចន្ទីនេះក៏មានការសំលាប់ផងដែរនូវអនិកជនយួន ។ លី ឃិននិយាយថាប្រសិនបើប្រុសយួនប្រពន្ធខ្មែរគឺត្រូវពួកខ្មែរក្រហមយកប្តីមកសំលាប់នៅស្វាយចន្ទីនេះ ហើយប្រសិនបើប្រពន្ធជាយួនប្តីខ្មែរក៏ត្រូវខ្មែរក្រហមយកប្រពន្ធមកសំលាប់មុនដែរ ហើយក្រោយមកយកប្តី ប្រពន្ធជាខ្មែរមកសំលាប់តាមក្រោយ ។

ថ្ងៃទី ២៥-៥-២០០០

វេលាម៉ោង៨ៈ៥៥នាទី ក្រុមដែនទីជួបជាមួយលោកឈុន ឡាជាប៉ូលីសស្រុកចំការលើដែលមានទីលំនៅ នៅភូមិថ្នល់បែកកើត ឃុំស្វាយទាប ស្រុកចំការលើ ។ ឈុន ឡាបាននិយាយប្រាប់ពីការសំលាប់មនុស្សនៅចំការស្វាយចន្ទីដល់ក្រុមយើងថាៈ

ថ្ងៃមួយក្នុងខែ៧ ឆ្នាំ១៩៧៨ ឈុន ឡាបានទទួលបញ្ជាពីប្រធានកងអោយដឹកយកមនុស្សពីរនាក់(ប្រជាជនថ្មី) ហៅតា៨០ទៅកាន់(ស្រឡៅពក) ដោយមានទិសដៅឆ្ពោះមកកាន់ទីតាំងសំលាប់ស្វាយចន្ទី ។ ឡា បានដឹកតា៨០ទាំងពីរនាក់រួមជាមួយរទេះគោ៣០ ៤០ផ្សេងទៀតក្នុងទិសដៅតែមួយ ។ ពេលធ្វើដំណើរមកជិតដល់កន្លែងសំលាប់ក៏បានឮស្គរសំលេងមេក្រូយ៉ាងទ្រហឹង ព្រមទាំងបានឮសំលេងយំរបស់ក្មេងៗ ។ នៅពេលដែលរទេះបរដល់ផ្លូវបំបែក(ផ្លូវមួយឆ្ពោះទៅៈស្រឡៅពក)ផ្លូវមួយទៀតចូលទីតាំងសំលាប់ស្វាយចន្ទីៈ ឡាបានឃើញសេនាជន (អាយុ១៥-១៦ឆ្នាំ) មួយចំនួនឈរឃាត់ផ្លូវមិនអោយរទេះទាំងនោះធ្វើដំណើរឆ្ពោះទៅ(ស្រឡៅពក)ទេ គឺបានបញ្ជាអោយកងរទេះទាំងនោះបត់ចូលក្នុងទីតាំងសំលាប់ស្វាយចន្ទី ។ ពេលចូលទៅកៀកនឹងកន្លែងសំលាប់មែនទែន ឈុន ឡាបានឃើញមេខ្មែរក្រហម២នាក់ក្នុងនោះមានម្នាក់ឈ្មោះ សួនកំពុងតែបញ្ជាអោយសេនាជនចូលទៅចងមនុស្សលើរទេះទាំងប៉ុន្មានយកទៅសំលាប់ចោល ។ ចំនែកកាបូប វ៉ាលីរបស់ជនរងគ្រោះត្រូវបានឈុន ឡាលើកគ្រវែងចេញពីរទេះទៅលើពំនូកឥវ៉ាមួយដែលមានកំពស់ប្រហែល៥ម៉ែត្រ តាមសំរែកបញ្ជារបស់ប្រធានកងប្រធានក្រុមនៅកន្លែងនោះ ។ បន្តិចក្រោយមកប្រធានកង, ប្រធានក្រុមទាំងនោះបានស្ទុះទៅលើកឥវ៉ាន់របស់ជនរងគ្រោះដើម្បីយកវត្ថុដែលពួកគេ(ប្រធានកង, ក្រុម) ចាត់ទុកថាជាវត្ថុមានតំលៃដូចជា អាវម៉ុងតេហ្កុយ, សារុងសូត្រ, ខោកាណាដា....ៗល ។ ឈុន ឡាបន្តថាបានឃើញសេនាជា២,៣នាក់ដើរចេញពីមាត់រណ្តៅមកអូសយកជនរងគ្រោះដែលចងួចយកទៅសំលាប់បន្តទៀត ។ សេនាជនទាំងនោះតាមសំដីរបស់ឈុន ឡា ថាមានកាន់ពូថៅមួយម្នាក់ដែលមានដៃវែង-ដងខ្លី ។ ឈុន ឡាសន្និដ្ឋានថាទំនងសំលាប់នឹងពូថៅនេះទៅលើជនរងគ្រោះ ។ ចំណែកស្ត្រីមានកូនខ្ចីបីនឹងដៃ ត្រូវពួកសេនាជនចងបន្ទូរដើម្បីទុកដៃបីកូនអោយជោ ។ ប៉ុន្តែប្រសិនបើស្ត្រីនោះចង់បត់ដៃដើងគឺត្រូវជុះដាក់សារុងដែលកំពុងស្លៀក ហើយត្រូវបានពួកសេនាជនទាំងនោះយកជើងទៅឆ្កឹះគូទស្ត្រីនោះបើសិនបត់ជើងយូរ ។ នេះជាសំដីរបស់ឈុន ឡាដែលបាននិយាយទាំងទឹកភ្នែករលីងរលោងប្រាប់យើង ។

ក្រោយមកបានប៉ុន្មានថ្ងៃឈុន ឡាត្រូវបានប្រធានឃុំឈ្មោះយ៉ុនហើយត្រូវជាប្រធានចាត់ចែងនៅទីតាំងសំលាប់ស្វាយចន្ទីហៅអោយមកប្រជុំនៅម៉ោង ៦ល្ងាចដើម្បីបំផុសកំលាំងអោយចូលរួមកំទេចខ្មាំងជួយគាំទ្របក្សនិងធ្វើឥរិយាបទត្រឹមត្រូវជួយលក្ខ័ការណ៍បក្ស ។ ឈុន ឡាភ័យស្ទើរលោះព្រលឹងខ្លាចក្រែងខ្មែរក្រហមយកមក

សំលាប់ដោយយកឡេសថាអោយមកប្រជុំ ។ ប៉ុន្តែកិច្ចប្រជុំក្រោមអធិបតេយ្យភាពឈ្មោះ យ៉ុនត្រូវបានបញ្ចប់ ហើយអនុញ្ញាតិអោយឈុន ឡាព្រមទាំងមនុស្សជាង២០នាក់ផ្សេងទៀតត្រលប់មកផ្ទះវិញ ។

ចុងបញ្ចប់នៃកិច្ចសំភាសន៍ឈុន ឡាបានបញ្ជាក់ថាភូមិទាំង១៣ក្នុងឃុំស្វាយទាបដលត្រូវយកប្រជាជនទៅសំលាប់នោះគឺភូមិថ្នល់បែកកើត, ថ្នល់បែកលិច, ស្រែពាល, ព្រឹកមហា, ត្រពាំងបេង, អូដារ, ស្វាយទាប, តាំងក្រូង, វាវីលិច, វាវីកើត, ត្រម៉ាត់ដី, និងភូមិចិន ។ ក្នុងចំណោមភូមិទាំង១៣នេះមានភូមិមួយគឺភូមិស្រែពាលមិនត្រូវបានសំលាប់ទាំងអស់ទេ ព្រោះកាលនោះ(ខែ៧, ១៩៧៨) ប្រធានភូមិភាគ៣០៤ឈ្មោះកែ ពកបានមកឃើញរួចក៏និយាយថា៖អ្នកណាអោយសំលាប់ អ្នកធ្វើអញ្ចឹង៖ នៅពេលដែលកែ ពកបានធ្វើដំណើរកាត់ផ្លូវហ្នឹង (ផ្លូវជាប់ទីតាំងសំលាប់ស្វាយចន្ទី) ។ ពេលនោះកែ ពកបានចាប់មេសង្កាត់ឈ្មោះ យ៉ុនយកទៅសំលាប់ចោលបន្ទាប់ពីពីរថ្ងៃក្រោយការសំលាប់ដែលមានទ្រង់ទ្រាយធំរួច ។

ឈុន ឡាត្រូវរួចខ្លួនពីសេចក្តីស្លាប់ចុងក្រោយនៅពេលដែលកែ ពកបញ្ជាអោយចុះឈ្មោះអ្នកចេះដឹងទាំងប៉ុន្មានក្នុងភូមិ(ឈុន ឡាក៏មានឈ្មោះដែរ) ប៉ុន្តែពេលនោះ(ចុងឆ្នាំ១៩៧៨) ឈុន ឡាលមាននិយាយម្នាក់ឈ្មោះយាយយឹមដែលជាជំនិតរបស់ប្រពន្ធឈុន ឡាជួយមិនអោយឈុន ឡាកត់ឈ្មោះទេដោយយកឡេសថាត្រូវជាប់សាច់ឈាម ។ ចំនែកអ្នកដែលបានចុះឈ្មោះរួចក៏ត្រូវបានសំលាប់តាមគំរោងផែនការដែរគឺត្រឹមតែនាំជនរងគ្រោះទាំងនោះដើរមើលរោងចក្រ, ទំនប់កំពង់ថ្ម,....ជំនួសទៅវិញ ព្រោះជិតបែកឆ្នាំ១៩៧៩ហើយ(សំលាប់មិនទាន់) ។

ក្រោយពីជួបលោកឈុន ឡាយើងបានបន្តដំណើរទៅជួបលោកប្រធានភូមិបែកកើតឈ្មោះហម គឹមសួរ នៅវេលាម៉ោង១០:១៥នាទី ។

ហម គឹមសួរមានអាយុ៥៩ឆ្នាំមានទីលំនៅនៅភូមិថ្នល់បែកកើត ឃុំស្វាយទាប ស្រុកចំការលើ ។ គឹមសួរប្រាប់យើងថាគាត់ជាអ្នកបរទេះដឹកមនុស្សចេញពីភូមិថ្នល់បែកកើតកាលពីជំនាន់ខ្មែរក្រហមជាអ្នកបញ្ជាអោយគាត់ដឹកមនុស្សយកទៅសំលាប់ ។ ប៉ុន្តែគាត់(គឹមសួរ)ដឹកចេញពីភូមិបានតែ៣០-៤០ម៉ែត្រប៉ុណ្ណោះក៏ត្រូវដឹកបន្តដោយកណៈកង គណៈក្រុមផ្សេងៗទៅកាន់ចំការស្វាយចន្ទី ។ ខោល ឆេងបានឡើងទៅគណៈឃុំជំនួសឈ្មោះយ៉ុនដែលកែ ពកបានបញ្ជាអោយសំលាប់ ។

យោងតាមសំដីគឹមសួរថាបានឃើញមិត្តអឿន ដែលត្រូវជាប្អូនថ្លៃរបស់កែ ពកដើរចូលទៅក្នុងរោងបាយមួយកន្លែងក្នុងភូមិថ្នល់បែកកើត ។ អឿនបាននិយាយថាហេតុអីបានជានាំគ្នាហូបបាយលាយចេកអញ្ចឹង? ពេលនោះអ្នកនៅក្នុងរោងបាយទាំងអស់នាំគ្នាត្រេកអរណាស់ ព្រោះនឹកស្មានថាថ្ងៃក្រោយប្រាកដជាបានបាយសុទ្ធស៊ី

ហើយ ប៉ុន្តែផ្ទុយស្រលះក្រោយពេលដែលមិត្តអឿនចេញទៅពីរោងបាយស្រាប់តែមានការកាត់បន្ថយបន្ថែមទៀត មិត្តអឿននិយាយរបៀបនេះនៅឆ្នាំ១៩៧៣-៧៤ ។

<u>សន្និដ្ឋានៈ</u>

ទីតាំងសំលាប់ចំការស្វាយចន្ទីមានៈ

- រណ្តៅធំស្ថិតនៅទិសខាងលិចក្នុងបរិវេណចំការស្វាយចន្ទី(ទំហំ ២៖៣០ជំរៅ១,៥-២ម៉ែត្រ) ចំនួន៣-៤, ចំលើយជនរងគ្រោះទាំងប៉ុន្មានខាងលើបញ្ជាក់ថាមានមនុស្សស្លាប់ប្រមាណពី៥០០០-៧០០០ នាក់ ។
- រណ្តៅគ្រាប់បែកចំនួន៣ស្ថិតនៅខាងជើងក្នុងបរិវេណចំការស្វាយចន្ទីមានទំហំផ្ចិតវង់៦ម៉ែត្រជំរៅ ២ ម៉ែត្រ មានមនុស្សស្លាប់ទាំង២០០នាក់សុទ្ធតែកងចល័តខ្មែរក្រហម ។
- រណ្តៅតូចៗជាច្រើនស្ថិតនៅជាប់ខាងកើតរណ្តៅធំទាំង៣-៤មានទំហំ១,៥៖២ម៉ែត្រ ជំរៅកន្លះម៉ែត្រ មិនអាចធ្វើការសន្និដ្ឋានបាននូវចំនួនមនុស្សស្លាប់ ព្រោះមានការសំលាប់ជារៀងរាល់ថ្ងៃ(គិតពីខែ៧ ១៩៧៨ បែក១៩៧៩) ។រណ្តៅតូចៗនេះមានសំលាប់ផងដែរនូវអនិកជនវៀតណាមទាំងគ្រួសារ ។ ចំណុះក្នុងមួយរណ្តៅៗមានពី២-៥នាក់ ។

អ្នកដឹងឮទាំងប៉ុន្មានខាងលើសុទ្ធតែបានសន្និដ្ឋានដូចៗគ្នា ថាទីតាំងសំលាប់ស្វាយចន្ទីនេះមានមនុស្សស្លាប់ ប្រមាណជាង១០,០០០នាក់ ។

ចំនែកអដ្ឋិធាតុនៅចំការស្វាយចន្ទីមានមិនបាន១ ៗ១០នៃអដ្ឋិធាតុនៅសល់ត្រូវបានប្រជាពលរដ្ឋជូនទៅរដ្ឋ អំណាចឃុំយកមករក្សាទុកនៅក្នុងវត្តស្វាយទាបក្នុងទស្សវត្សទី៨០ ប៉ុន្តែបច្ចុប្បន្នខ្ទាត់ខ្ទាយអស់គ្មានសល់ឡើយ ដោយសារតែមានការរុះរើទីវត្តអារាម ។

២-<u>ទីតាំងសំលាប់ឡូ ១៨ (ថ្ងៃទី ២៥-៥-២០០០)</u>

នៅរសៀលថ្ងៃដដែល(២៥-៥-២០០០)បន្ទាប់ពីញ៉ាំបាយថ្ងៃត្រង់រួចក្រុមយើងបានបន្តដំណើរឆ្ពោះមក ទីតាំងសំលាប់មួយទៀតហៅថាឡូ ១៨ ។ ឡូ១៨ស្ថិតក្នុងភូមិ៣២មូលដ្ឋានស្វាយមាស ស្រុកចំការលើ ខេត្ត កំពង់ចាម ។

មកដល់មុខក្លោងទ្វារមូលដ្ឋានស្វាយមាស យើងបានជួបជាមួយអ៊ីម្នាក់ឈ្មោះយ៉ាន់ យ៉ុម អាយុ៤៨ឆ្នាំ កំពុងអង្គុយក្នុងតូបយាមមួយជាប់នឹងក្លោងទ្វារមូលដ្ឋានស្វាយមាស ។ លោកអ៊ីមានស្រុកកំណើតនៅខេត្តតាកែវ

ហើយបច្ចុប្បន្នរស់នៅភូមិ៣២ មូលដ្ឋានស្វាយមាស ស្រុកចំការលើ ។ លោកអ៊ំបានប្រាប់ថា កាលពីជំនាន់ប៉ុលពត(មិនចាំឆ្នាំ) ពេលដែលគាត់កំពុងជៀរជ័រកៅស៊ូក៏បានប្រទះឃើញមានឡានដឹកអ្នកទោសនោះច្រើន តែដឹកមកដល់ពេលយប់ប្រហែលជាម៉ោង៧-៨ ។ ប្រជាជនទាំងនោះមិនត្រូវបានពួកខ្មែរក្រហមឃុំទុកទេសូម្បីតែមួយយប់ឡើយ គឺត្រូវសំលាប់ភ្លាម ។ អ្នកដែលបានមកស្លាប់នៅទីនេះច្រើនតែប្រជាជនថ្មីមកពីគ្រប់ឃុំក្នុងស្រុកចំការលើព្រមទាំងមកពីបណ្តាស្រុកផ្សេងទៀតក្នុងខេត្តកំពង់ចាម ។ អ៊ំយ៉ាន់ យ៉ុមបានសន្និដ្ឋានថាមានជិត២០រណ្តៅដែលមានទំហំ៥៖១០ម៉ែត្រជំរៅ២ម៉ែត្រ ។ រំពេចនោះលោកស៊ឹម លីដែលជាប្រជាជនរស់នៅភូមិជាមួយយ៉ាន យ៉ុមដែរបានប្រាប់ថានៅពេលដែលគាត់ទទួលបញ្ជាអោយមកយកបែរដាក់ជ័រកៅស៊ូនៅក្បែររណ្តៅក៏បានប្រទះឃើញមានខ្សែជក់បារី, កាបូប, ក្រឡប្រហុក.....។ល ។ ស្ថិនៅពាស់វាលពាសកាលក្បែរៗរណ្តៅព្រមទាំងឃើញសាកសពថ្មីៗទៀតផង ។ ស៊ឹម លីបាននិយាយបន្តថា ការសំលាប់របស់ខ្មែរក្រហមមកលើប្រជាជនគឺគៀបកនឹងធៀងត្នោតនៅចំកណ្តាលរណ្តៅ ព្រោះខ្មែរក្រហមបានធ្វើស្ពានមួយដាក់ចំកណ្តាលរណ្តៅពីម្ខាងទៅម្ខាងហើយដាក់ឃ្នាបគៀបនៅពីលើដោយចងភ្ជាប់ជាមួយបង្គោលមួយ ។ ពេលសំលាប់ពួកខ្មែរក្រហមបានអោយអ្នកទោសចូលកទៅក្នុងឃ្នាបនោះរួចខ្មែរក្រហមក៏គៀបបំបែកបំពង់កតែម្តង ។ មិនតែប៉ុណ្ណោះនៅមានរណ្តៅផ្សេងៗទៀតជាច្រើនដែលខ្មែរក្រហមសំលាប់មនុស្សតាមរបៀបផ្សេងៗ ដូចជាចាក់មេក្រូបំភាន់បន្ទប់រួចវាយនឹងគល់ឬស្សី...។ល ។ ចំនែកគំនរខោអាវរបស់ប្រជាជនដែលបានចាញ់បញ្ឆោតខ្មែរក្រហមថាផ្លាស់ប្តូរទីលំនៅហើយត្រូវមកសំលាប់នៅទីនេះត្រូវពួកខ្មែរក្រហមដុតចោលទាំងអស់ក្រោយពីការឆែកឆេររកមាស, ពេជ្ររួម ។ គំនរផេះក្រោយពីការដុតខោអាវស៊ឹម លីបានប្រាប់ថាមានកំពស់ស្មើនឹងទ្រូងមនុស្សចាស់(ជាងមួយម៉ែត្រ) ។

ក្រោយពីបានសាកសួរពត៌មានរួចលោកស៊ឹម លីបានជូនដំណើរក្រុមស្រាវជ្រាវនៅពិនិត្យដល់ទីតាំងឡូ ១៨ ដែលគាត់បានប្រាប់រួចមកហើយ ។ ទៅដល់ទីតាំងយើងពិនិត្យឃើញថាជាក់ស្តែងនូវរណ្តៅមួយចំនួនដែលនៅមានស្នាកស្នាមនៅឡើយ ។ ជាក់ស្តែងនៅរណ្តៅមួយនោះស្ថិតនៅក្នុងចំការកៅស៊ូទើបដាំថ្មី ប៉ែកខាងលិចចំការកៅស៊ូចាស់(ក្នុងឡូ១៨) នៅមានសសសល់ធ្មេញ+ខ្សែរអាវខ្លះៗ ។

ចំពោះការសន្និដ្ឋាននៅលើចំនួនសាកសព, ស៊ឹម លី មិនអាចធ្វើការសន្និដ្ឋានបានឡើយ ប៉ុន្តែស៊ឹម លីបាននិយាយថាមនុស្សដែលបានស្លាប់នៅឡូ១៨នេះមានចំនួនច្រើន ព្រោះមកពីបណ្តាលឃុំ ស្រុកនានាក្នុងខេត្តកំពង់-ចាម ។ ជាក់ស្តែងពីឆ្នាំ១៩៧៥-១៩៧៧ប្រជាជននៅឃុំស្វាយទាបចំនួន៥០០គ្រួសារក៏បានមកស្លាប់នៅឡូ ១៨ នេះដែរ ។

**ស្រុកព្រៃឈរៈ** *(ថ្ងៃទី២៦-៥-២០០០)*

១. <u>មន្ទីរសន្តិសុខមិត្ត សុបៈ</u>

ស្ថិតនៅក្នុងភូមិតាកែវ ឃុំគរ ។ មន្ទីរនេះជាមន្ទីរសន្តិសុខតំបន់៤១ក្នុងភូមិភាគកណ្តាលដែលមានអាគារ៤ខ្នងសង់ជាលក្ខណៈសាលារៀន, ដំបូលប្រក់ក្បឿង ជញ្ជាំងក្តារដែលមានទំហំក្នុងមួយខ្នងៗប្រវែង១២ម៉ែត្រ និងទទឹង៦ម៉ែត្រ ។ មន្ទីរនេះគ្រប់គ្រងដោយមិត្តសុប ។ មិត្តសុប មានស្រុកកំណើតនៅឃុំសំរោង ស្រុកព្រៃឈរ ។

បច្ចុប្បន្នមន្ទីរសន្តិសុខដែលមានផ្ទៃដី៦០,១០០នេះក្លាយជាដីកម្មសិទ្ធិរបស់លោកតាហ៊ុលយាយសៀប ។ ក្រោយពីបានទៅពិនិត្យផ្ទាល់ទើបដឹងថាដីនោះ(មន្ទីរសន្តិសុខមិត្តសុប) បានបន្សល់នូវស្រះទឹកចំនួនបីដែលជីកដោយកំលាំងអ្នកទោសកាលពីខ្មែរក្រហមនៅកាន់អំណាច ។ ម៉្យាងទៀតទីតាំងនេះបច្ចុប្បន្នជាកន្លែងមួយដែលមានទួលខ្ពស់ព្រមទាំងមានម៉ុងខ្មោចចិនជាច្រើនផងដែរ ។

នៅលើទីទួលនៃអតីតមន្ទីរសន្តិសុខមិត្តសុប យើងបានជួបជាមួយលោកពូម្នាក់ដែលជាជិទប់លេខពីឃុំគរឈ្មោះណៃ គឹមសាន់ ។ លោកពូមានអាយុ៥៣ឆ្នាំមានស្រុកកំណើតនៅភូមិតាមាស ឃុំគរ ស្រុកព្រៃឈរ ។ ជំនាន់ប៉ុល ពតនិងបច្ចុប្បន្នលោកពូរស់នៅភូមិនេះដដែល ។ លោកពូបានប្រាប់យើងថាកាលពីជំនាន់ប៉ុល ពតមន្ទីរសន្តិសុខមិត្តនេះដាក់អ្នកទោសភាគច្រើនជាអ្នកជាប់និន្នាការទាហានលន់ ណុល ។អ្នកទោសទាំងនោះត្រូវបានសម្លាប់ដោយពួកអ្នកយាមគុកដោយប្រើដំបងឈើ ដែកជាឧបករណ៍សំលាប់ ។ ចំនែកការហូបចុកវិញលោកពូណៃ គឹម-សាន់ប្រាប់ថាគ្មានចាននិងស្លាប់ព្រាសំរាប់បរិភោគបាយទេគឺដាក់នឹងស្លឹកចេកអោយបរិភោគ ថែមទាំងមិនបានដោះខ្នោះចេញទៀតផង ។ អ្នកទោសទាំងអស់តំរូវអោយដាក់ខ្នោះជាប់ជារៀងរាល់ថ្ងៃ ។ ប្រសាសន៍របស់លោកពូបានបន្តថា ខ្នោះដែលដាក់អ្នកទោសនោះមិនមែនជាខ្នោះដែកទេ គឺជាខ្នោះឈើដែលមានទំហំ៥,១៥ហ៊ុនហើយចោះប្រហោងសំរាប់ដាក់កជើង រួចមានបន្ទះឈើមួយទៀតដែលមានទំហំល្មមគ្របពីលើរួចចាក់សោរមិនអោយជើងចេញបាន ។ ទាំងពេលបាយ, ពេលបត់ជើង, ពេលដេកគឺមិនត្រូវបានដោះខ្នោះចេញឡើយ, តាមសំដីរបស់លោកពូគឹមសាន់ថាអ្នកទោសទាំងអស់គ្មានគ្រែសំរាប់ដេកទេ(ដេកផ្ទាល់នឹងដី) ហើយពេលបត់ជើងធំម្តងៗ គឺមានពងតូចមួយល្មមម្នាក់មួយសំរាប់ដាក់លាមកខ្លួនឯងដោយគ្រាន់តែរំកិលគូទដាក់អោយចំមាត់ពាងដែលស្ថិតនៅក្បែរខ្លួនទៅជាការស្រេច ។

ក្នុងមន្ទីរសន្តិសុខមិត្តសុបនេះមិនដែលមានការប្រជុំឬបំពាក់បំប៉នអ្វីដល់អ្នកទោសឡើយក្រៅពីចេញទៅធ្វើការនៅម៉ោង៧ព្រឹក អ្នកទោសទាំងអស់ត្រូវដេកជាប់ខ្នោះនៅមួយកន្លែង ។ លោកពូណៃ គឹមសាន់ បន្តថាអ្នកទោសដែលជាប់ក្នុងមន្ទីរនេះគ្មាននរណាម្នាក់អាចរួចខ្លួនបានទេគឺត្រូវសំលាប់ទាំងអស់ រួចសែងយកទៅកប់នៅតាម

កន្លែងមួយចំនួនដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីបរិវេណមន្ទីរសន្តិសុខនេះ ដូចជានៅទីតាំងទួលក្រសាំង, ត្នោតជួរ, អូរតាគង់និងទួលដើមអំពិល ។

២. <u>ទីតាំងសំលាប់:</u>

ក. <u>អូតាគង់:</u>

ជាអូរឬប្រឡាយទឹកមួយដែលលាតសន្ធឹងពីភូមិតាមាសដល់ស្ទឹងទីឆាមានប្រវែងប្រហែល១០០០ម ។ អូរនេះស្ថិតនៅជាប់ព្រំប្រទល់ភូមិតាមាសនិងភូមិតាកែវ ឃុំគរ ហើយក្លាយទៅជាកន្លែងដាក់សាកសពតាំងពីឆ្នាំ១៩៧៥មក ។ លោកពូណៃ គឹមសាន់បានប្រាប់ថាមានសាកសពប្រហែល១០០០នាក់ត្រូវបានពួកខ្មែរក្រហមសំលាប់ រួចយកមកគំរៀបក្នុងអូរនេះដែលមានជំរៅ១ម.និងទទឹងពី២-២,៥ម. ។ លោកពូបន្តទៀតថាសាកសពទាំងនោះមិនបានកប់ដីពីលើទេ ។ អ្នកដែលបានស្លាប់ក្នុងអូរនេះច្រើនតែជាអ្នកជាប់និន្នាការ និងកម្មាភិបាលខ្មែរក្រហមដែលបានខុសសីលធម៌ ។ បច្ចុប្បន្នអូរស្តុបទឹកសំរាប់ធ្វើស្រែ ។

ខ. <u>ទួលក្រសាំង:</u>

ស្ថិតនៅក្នុងទឹកដីភូមិតាកែវ, ឃុំគរ ។ ទួលនេះមានទំហំ៥០៖១០០ម. ហើយបច្ចុប្បន្នមានដើមក្រសាំងជាសំគាល់ ។ តាមសំដីលោកពូណៃ គឹមសាន់ថាកាលពីសម័យប៉ុល ពតខ្មែរក្រហមកាន់អំណាចទួលនេះជាទួលសំលាប់មនុស្សនិងកប់មនុស្សជាច្រើននាក់ ។ មានរណ្តៅច្រើនណាស់នៅលើទួលនេះ តាមការប៉ាន់ស្មានរបស់គឹមសាន់ថាមានដល់ទៅរាប់រយរណ្តៅឯណោះ ហើយចំនួនសាកសពមានចំនួនរហូតដល់ទៅជិត១០០០នាក់ដូចទីតាំងអូរតាគងដែរ ។ លោកពូបន្ថែមថាក្នុងមួយរណ្តៅៗមានសាកសពពី៣-៥នាក់ ។ ទីតាំងនេះស្ថិតនៅខាងលិចគុកសន្តិសុខមិត្តសុបប្រហែល៥០០ម. និងស្ថិតនៅខាងលិចឈៀងខាងជើងទីតាំងអូរតាគង ។

គ. <u>ត្នោតជួរ:</u>

ទីតាំងនេះក៏ស្ថិតនៅក្នុងភូមិតាកែវ ឃុំគរដែរ ប៉ុន្តែស្ថិតនៅទិសខាងត្បូងទីតាំងអូរតាគង់ប្រហែលជា៥០០ម. និងមានចំងាយប្រហែល២០០ម.ពីមន្ទីរសន្តិសុខមិត្តសុប ។ ទួលត្នោតជួរមានទំហំដីប្រមាណ២០០ម. បួនជ្រុងដែលមានពី៧០-៨០រណ្តៅ ហើយក្នុងមួយរណ្តៅៗមានជំរៅពី២-៣ម. និងមានទំហំ២ម.បួនជ្រុង ។ ណៃ គឹមសាន់បញ្ជាក់ថា សាកសពដែលបានស្លាប់នៅទីនោះមានប្រហែលជាពី២៤០-៣០០នាក់ ។

ឃ. <u>ទួលដើមអំពិល:</u>

ទួលនេះស្ថិតនៅក្នុងភូមិតាកែវ ឃុំគរជាប់នឹងព្រំប្រទល់ភូមិតាមាស ។ ទីតាំងនេះនៅជាប់ជាមួយនិងទីតាំងអូរតាគង់តែម្តង, បច្ចុប្បន្នមានដើមអំពិលជួរមួយដើមជាសំគាល់ ។ ណៃ គឹមសាន់និយាយថាមាន២០រណ្តៅ ក្នុងមួយរណ្តៅៗមានទំហំ២,៣ម. ដែលមានផ្ទុកសាកសពពី៣-៤នាក់ ។ លោកពូគឹមសាន់ក៏បានធ្វើការសន្និដ្ឋានថារណ្តៅទាំង ២០ នេះមានសាកសពសរុបប្រហែល៨០នាក់ ។

ង. <u>ទីតាំងសំលាប់នៅក្នុងសាលាបឋមសិក្សាប៊ុន រ៉ានីហ៊ុនសែន ឃុំគរៈ</u>

ស្ថិតនៅក្នុងភូមិតាម៉ូត ឃុំគរ ស្រុកព្រៃឈរ ។ កាលពីជំនាន់សីហនុ ក៏ជាសាលាបឋមសិក្សាដែរ ហើយរហូតមកដល់ជំនាន់ប៉ុល ពតសាលានេះក៏ក្លាយជាកន្លែងសំលាប់មនុស្សនិងកប់មនុស្សជាច្រើនរយនាក់ ។ អាគារមួយខ្នងស្ថិតនៅខាងមុខគេក្នុងចំនោមអាគារទាំងបីខ្នងទន្ទឹមគ្នាប៉ែកខាងកើត កាលពីឆ្នាំ១៩៧៥-៧៩ជាអាគារសំរាប់ស្តុបអ្នកទោសនិងសំលាប់អ្នកទោស ។ ក្រោយពីបែកឆ្នាំ១៩៧៩អាគារមួយខ្នងនេះនៅមានស្នាមឈាមប្រឡាក់ជញ្ជាំងព្រមទាំងមាននៅសេសសល់នូវវត្ថុតាងសំរាប់សំលាប់អ្នកទោសដូចជាដំបងជង ប៉ុន្តែយ៉ាងហោចណាស់ក៏ធ្វើអោយមនុស្សវ័យចំនាសៗភាគច្រើនដែលក្នុងភូមិ ឃុំខាងលើនៅតែនឹកឃើញនូវការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃរបស់ពួកខ្មែរក្រហមមកលើប្រជាជនស្លូតត្រង់កាលពីឆ្នាំ១៩៧៥-៧៩ដែរ ។ ជាក់ស្តែងលោកណៃ គឹមសាន់បាននាំក្រុមយើងទៅមើលផ្ទាល់ដល់អាគារមួយខ្នងនេះ ព្រមទាំងបានរៀបរាប់ប្រាប់យើងពីការសំលាប់មនុស្សនាពេលនោះ(១៩៧៥-១៩៧៩) នៅក្រោយឆ្នាំ១៩៧៥ប្រជាជនត្រូវពួកខ្មែរក្រហមជំលៀសចេញអោយនៅភូមិផ្សេងៗ ហើយយកប្រជាជនថ្មី(១៧ មេសា) មកដាក់ជំនួសវិញ ពិសេសនៅភូមិភាគតាកែវនិងភូមិភាគតាមាស ។ ការស្នាក់នៅនៃប្រជាជនថ្មីទាំងនោះមិនបានយូរឡើយ គឺត្រូវពួកខ្មែរក្រហមដឹកទាំងយប់(ម៉ោង១២យប់)មកកាន់សាលាបឋមសិក្សានេះរួចហើយក៏ធ្វើការសំលាប់តែម្តង ។ ប្រជាជនដែលបានដឹកមកកាន់សាលានេះសុទ្ធតែត្រូវចាញ់បោកពាក្យឃោសនារបស់ខ្មែរក្រហមថាឲ្យមកប្រជុំ ។ ក្រោយពីការសំលាប់សាកសពទាំងនោះត្រូវបានពួកខ្មែរក្រហមអូសយកមកដាក់ក្នុងបន្ទន់មួយដែលស្ថិតនៅខាងជើងអាគារ(ដែលពួកខ្មែរក្រហមយកធ្វើជាកន្លែងសំលាប់មនុស្សកាលនៅកាន់កាប់) ប្រហែលជា១០០ម. ។ ជនដៃដល់ក្នុងការសំលាប់ប្រជាជនកាលនោះឈ្មោះតែមនិងឈ្មោះដន ។ ចំនួនសាកសពក្នុងបន្ទន់នេះលោកពូណៃ គឹមសាន់បានបញ្ជាក់ថាមានចំនួនប្រហែលជា២០០នាក់(បូករួមទាំងក្នុងបន្ទប់បន្ទន់និងលូរបន្ទន់) ។ ចំនែកឯបរិវេណជិតៗបន្ទន់ជាពិសេសប៉ែកខាងលិចបន្ទន់ ក៏មានរណ្តៅច្រើនផងដែរ ដូចលោកពូណៃ គឹមសាន់និយាយថាមានរណ្តៅចំនួន៦០ក្នុងទំហំដីជាង១០០ម. ។ រណ្តៅនីមួយៗមានទំហំ១,២ម. ជំរៅ១ម. ជីកជាបីជួរ(ក្នុងមួយជួរមាន២០រណ្តៅ) ។ សាកសពសរុបទាំង៦០រណ្តៅនេះមានចំនួនប្រហែល២៥០នាក់ ។

លោកពូណៃ គឹមសាន់ក៏បានបញ្ជាក់ផងដែរពីករណីទីវ ម៉ីដែលត្រូវពួកខ្មែរក្រហមយកទៅសំលាប់ ។ ទីវ ម៉ីត្រូវពួកខ្មែរក្រហមយកទៅសំលាប់នៅខែ៣ ៤ឆ្នាំ១៩៧៥ដោយចោទថាជាអ្នករដ្ឋការចាស់ ។ លោកពូនិយាយថាពេលដែលខ្មែរក្រហមមកចាបទីវ ម៉ីនៅពេលព្រលប់រួចបណ្តើរគាត់តាមសាលារៀនបឋមសិក្សាខាងលើស្រាប់តែទីវ ម៉ីស្រែកថា «អាម៉ីកូនជាងឃឹមគេយកទៅសំលាប់ហើយ» ។ សម្រែករបស់ទី ម៉ី ០វានធ្វើឲ្យជនរងគ្រោះដទៃទៀតតក់ស្លុតយ៉ាងខ្លាំង ។ តាមសំដីរបស់លោកពូ ណៃ គឹមសាន់ ថាឈ្មោះ តែម ជាជនដៃដល់ក្នុងការសម្លាប់ទីវ ម៉ី ។ គាត់បានបន្តថា ទីវ ម៉ី បានទាញគ្រាប់បែក(ផ្លែទឹកដោះ) បម្រុងគប់ទៅលើពួកខ្មែរក្រហមដែលមកចាប់ ទីវ ម៉ី ប៉ុន្តែមិនទាន់បានគប់ផង ក៏ត្រូវទាហានខ្មែរក្រហមចាប់បាន ។ ណៃ គឹមសាន់ថាពេលខ្មែរក្រហមបណ្តើរ ទីវ ម៉ីទៅសម្លាប់ស្រាប់តែ ទីវ ម៉ីទាត់ពួកខ្មែរក្រហមម្នាក់ស្លាប់ ។

ក្នុងពេលដដែលនោះ ក្រុមយើងបានជួបជាមួយលោកនាយករងសាលាបឋមប៊ុនរ៉ានីហ៊ុនសែនឃុំគរឈ្មោះ ហោ គឹមសុង ។ លោកនាយករងបានប្រាប់ថានៅក្នុងបរិវេណសាលានេះ ជាពិសេសនៅត្រង់បង្គន់និងជិតបង្គន់មានការសម្លាប់ទាហានលន់ណុលដែលបានចុះចូលជាមួយនឹងខ្មែររំដោះ(ខ្មែរក្រហម) នៅបន្ទាយតាំងគោកកាលពីឆ្នាំ១៩៧៣ ។ ឪពុកមាររបស់លោកនាយករងបានប្រាប់គាត់ថាពួកខ្មែរក្រហមបានចាប់ផ្តើមសម្លាប់ទាហានលន់ណុលនៅក្នុងបរិវេណសាលានេះតាំងពីឆ្នាំ១៩៧១មកម្ល៉េះ ។ ទាហានដែលបានស្លាប់នៅកន្លែងនេះតាំងពីឆ្នាំ១៩៧១-១៩៧៤មានចំនួនប្រហែលរាប់ពាន់នាក់ ។ វិធីសម្លាប់របស់ខ្មែរក្រហមនៅពេលនោះគឺប្រើកាំរទេះគោជាឧបករណ៍សម្លាប់ ។ ម៉ោងប្រហែល៦-៧យប់ជាពេលដែលខ្មែរក្រហមយកទាហានមកសម្លាប់ ។

នៅវេលាម៉ោង១១ៈ៤០នាទីព្រឹក ក្រុមយើងបានចាកចេញពីសាលាបឋមសិក្សាប៊ុនរ៉ានីហ៊ុនសែនឃុំគរនិងទីតាំងសម្លាប់ទាំង៤ខាងលើឆ្ពោះទៅកាន់ផ្សារដើម្បីបរិភោគអាហារថ្ងៃត្រង់ ។ បន្ទាប់ពីបរិភោគអាហាររួចក្រុមយើងបានបន្តដំណើរទៅកាន់ទីតាំងមយយកន្លែងទៀតដែលស្ថិតនៅក្នុងឃុំថ្មពូន ស្រុកព្រៃឈរដែរ ។

មន្ទីរសន្តិសុខស្រុក៧៧លើ

ក្រោយពីបានអង្គុយលេងជាមួយប្រធាននគរបាលឃុំថ្មពូនក្នុងទីស្នាក់ការនគរបាលប៉ុស្តថ្មពូនអស់រយៈជិតមួយម៉ោងមក យើងបានជួបជាមួយលោកជំនួយការឃុំថ្មូនឈ្មោះ ងិន ណារី ។ ណារី មានអាយុ៣៨ឆ្នាំមានអាស័យដ្ឋានទាំងបីជំនាន់រស់នៅក្នុងភូមិអណ្តូងតាពេជ្រ ឃុំថ្មពូន ស្រុកព្រៃឈរ ។ លោកពូមានប្រសាសន៍ថានៅក្នុងឃុំថ្មពូនមានទីតាំងគុកសន្តិសុខមួយកន្លែង និងទីតាំងសម្លាប់មយយកន្លែងដែរគឺស្ថិតនៅខាងកើតសាលាឃុំថ្មពូនប្រហែល១៥០ម៉ែត្រ ។ កាលបីដើមឡើយមន្ទីរសន្តិសុខនេះគឺជាផ្ទះរបស់ប្រជាជនម្នាក់ឈ្មោះ អ៊ឹម ចន (បច្ចុប្បន្នស្លាប់) ។ ផ្ទះ អ៊ឹម ចន បានក្លាយទៅជាមន្ទីរសន្តិសុខតាំងពីឆ្នាំ១៩៧៣មកម្ល៉េះ ។ ប្រភេទជនរងគ្រោះ

ដែលបានជាប់នៅក្នុងមន្ទីរនេះច្រើនជាអ្នកខុសសីលធម៌ ទាហានលន់ណុល...។ល។ មន្ទិរនេះត្រូវរលាយទៅវិញនៅឆ្នាំ១៩៧៨ ហើយក៏ក្លាយទៅជាកន្លែងចិញ្ចឹមគោវិញ។ អ្នកគ្រប់គ្រងមន្ទីរនេះមានពីរនាក់គឺ ភិន និង ផាន់។ ភិន គ្រប់គ្រងតាំងពីឆ្នាំ១៩៧៣-៧៦ ឯចំណែក ផាន់វិញគ្រប់គ្រងបន្តពី ភិន រហូតដល់ឆ្នាំ១៩៧៨។

**ទីតាំងសម្លាប់អណ្តូងតាផាន់**

ស្ថិតនៅខាងកើតឈៀងខាងត្បូងប្រហែល១៥០ម៉ែត្រពីមន្ទីរសន្តិសុខស្រុក៧៧លើ។ ទីតាំងនេះគ្មានរណ្តៅទេ មានតែអណ្តូងមួយឈ្មោះថាអណ្តូងតាផាន់។ អណ្តូងពានេះ លោកណារី មិនអាចសន្និដ្ឋានពីទំហំនឹងជំរៅបានទេ ប៉ុន្តែលោក ណារី បាននិយាយថាមានមនុស្សស្លាប់ប្រហែល១០០នាក់នៅក្នុងអណ្តូងនេះ។

## ស្រុកបាធាយ

១) មន្ទីរសន្តិសុខវត្តប្រើសមាស

យោងតាមចម្លើយរបស់អ្នកដឹងហេតុការណ៍ច្បាស់ចំនួនពីរនាក់គឺ ញឹប ញៀប ជាប្រជាជនរស់នៅក្នុងភូមិថ្កូវ ឃុំត្រប់ ស្រុកបាធាយនឹងលោកមាច ផាញ់ អាយុ៥៣ឆ្នាំ ជាមេឃុំត្រប់ថា មានមន្ទីរសន្តិសុខមួយកន្លែងស្ថិត នៅក្នុងបរិវេណវត្តប្រើសមាស។ កុដិមួយដ៏ធំនៃវត្តប្រើសមាសត្រូវបានពួកខ្មែរក្រហមយកធ្វើជាកន្លែងឃុំឃាំងមនុស្សនិងធ្វើទារុណកម្មមនុស្សតាំងពីឆ្នាំ១៩៧៦មក។ សព្វថ្ងៃកុដិមួយនេះមិនត្រូវបានកម្ទេចចោល ឬកែទ្រង់ទ្រាយដើមទេ។ ចំពោះការធ្វើទារុណកម្ម និងសម្លាប់ពួកខ្មែរក្រហមច្រើនយកដំបង កាំបិត ត្បូងចបមកធ្វើជាឧបករណ៍។ អ្នកទោសដែលជាប់ក្នុងមន្ទីរឃុំឃាំងនេះច្រើនជាប្រជាជនថ្មី អ្នកខុសសីលធម៌ព្រមទាំងប្រជាជនចាស់ខ្លះដែលបានលួចដំឡូងជាដើម។

២) ទីតាំងសម្លាប់

លោកមេឃុំត្រប់ និង ញឹប ញៀប បានប្រាប់ថាជុំវិញបរិវេណមន្ទីរសន្តិសុខវត្តប្រើសមាសមានបីទីតាំងគឺៈ

-ចម្ការតាតាំងៈ ស្ថិតនៅក្នុងភូមិត្រប់ ឃុំត្រប់ ស្រុកបាធាយ។ មានបួនរណ្តៅដែលមានទំហំពីរម៉ែត្រទទឹង និងបួនម៉ែត្របណ្តោយក្នុងរណ្តៅមួយៗ។ អ្នកស្លាប់មានពី២០-៣០នាក់។

-ខាងកើតវត្តប្រើសមាសៈ មានពីររណ្តៅដែលមានទំហំ២ម៉ែត្រទទឹងនិង៤ម៉ែត្របណ្តោយ។សាកសពរួមមានប្រហែលជាង១០នាក់។

- ខាងក្នុងខ្លោងទ្វារវត្តប្រើសមាសៈ មានតែមួយរណ្តៅទេដែលមានសាកសព៣នាក់ ។ ទំហំរណ្តៅ២ម៉ែត្រទទឹងនិង៤ម៉ែត្របណ្តោយ ។

មេឃុំត្រង់ក៏បានបញ្ជាក់ដែរថា នៅក្នុងឃុំត្រង់ បើយោងទៅតាមការស្រង់ស្ថិតិអ្នកស្លាប់តាមគ្រួសារមានចំនួនដល់ទៅ១៥០០នាក់ ប៉ុន្តែលោកមេឃុំបន្តទៀតថា អ្នកទាំង១៥០០នាក់នោះមិនមែនស្លាប់នៅក្នុងឃុំត្រប់នេះតែមួយកន្លែងទេ គឺត្រូវបានពួកខ្មែរក្រហមដឹកទាំងឡានៗទៅសម្លាប់ចោលនៅភ្នំប្រុសភ្នំស្រីអស់មួយចំនួនធំ ។ មេឃុំរូបនោះក៏បានបន្ថែមថា នៅមានទីតាំងសម្លាប់មួយទៀតឈ្មោះថា ទួលភ្លើងឆេះ ហៅថា ទួលប្រាសាទចាមដែលស្ថិតនៅក្នុងភូមិភ្នំតូច ឃុំត្រប់ ។ ទីតាំងនេះជាទីតាំងសម្លាប់មួយក្នុងឃុំត្រប់ដែលមានមនុស្សស្លាប់ប្រហែល១០០នាក់ ។ ប្រជាជនដែលបានមកស្លាប់នៅទីនេះ លោកមេឃុំប្រាប់ថាច្រើនជាប្រជាជន១៥មេសា ។

បន្ទាប់ពីបញ្ចប់កិច្ចសម្ភាសន៍ជាមួយលោកមេឃុំត្រប់ និងញ៉ឹប ញៀបមក ក្រុមយើងបានបន្តដំណើរទៅពិនិត្យជាក់ស្តែងនូវអំពីទីតាំងទាំងប៉ុន្មានខាងលើព្រមទាំងមន្ទីរសន្តិសុខមួយផង ។ ជាចុងក្រោយយើងបានទៅពិនិត្យទីតាំងទួលប្រាសាទចាមទៀត ។ នៅក្បែរទួលនេះប្រហែល២០០ម៉ែត្រ យើង០ានជួបជាមួយលោកតាម្នាក់ជាប្រជាជនដែលរស់នៅក្នុងភូមិតាព្រង ឃុំត្រប់ ស្រុកបាធាយ ។ គង់ យិន ជាឈ្មោះរបស់លោកតានោះគាត់មានអាយុ៦៧ឆ្នាំ ។ លោកតាបានប្រាប់យើងដូចលោកមេឃុំប្រាប់ដែរប៉ុន្តែលោកតាបានបន្ថែមថាការសម្លាប់មនុស្សនៅទួលប្រាសាទចាមនេះធ្វើឡើងនៅចុងឆ្នាំ១៩៧៥ ។ អ្នកទោសច្រើនបណ្តើរមកទាំងខ្សែៗដោយមានចងស្លាប់សេកនិងដោតខ្សែក្រោមឃ្លៀក,ជាជួរៗមក ។ ក្នុងមួយជួរៗ លោកតាប្រាប់ថាមានចំនួនពី២៥ទៅ៣០នាក់ ហើយបណ្តើរម្តងៗមានពីបីទៅបួនខ្សែមកសម្លាប់នៅទីតាំងនេះ ។ អ្នកទោសទាំងនោះភាគច្រើនជាប្រុសៗ ។ លោកតាក៏បានបញ្ជាក់ដែរថា ទីតាំងនេះក៏មានសម្លាប់នូវទាហានលន់ណុលដែរ ដែលពួកទាហានខ្មែរក្រហមចាប់បាននៅក្នុងសង្គ្រាមនៅព្រៃគ្រីខេត្តកំពង់ឆ្នាំង ។ អ្នកណើ្តរប្រជាជនមកសម្លាប់ឈ្មោះ ស្រ៊ន, ឡុន, និងថេន ។ នៅទួលប្រាសាទចាមមានរហូតដល់ទៅ១៥ទៅ១៦រណ្តៅ ហើយក្នុងមួយរណ្តៅៗមានដាក់សាកសពពី២-៣នាក់ ។ វិធីសម្លាប់របស់ពួកខ្មែរក្រហមមកលើអ្នកទោសគឺដំបង, ត្បូងចប, គល់ឫស្សី, ដាវ.....។ល ។ សាកសពរួមនៅទួលប្រាសាទចាម លោកតាបានប្រាប់ដូចលោកមេឃុំដែរថាមានចំនួនប្រហែល១០០នាក់ ។

### ទីតាំងដែលពុំទាន់បានធ្វើការស្រាវជ្រាវ

មានមួយកន្លែងស្ថិតនៅក្នុងភូមិរំដួល ជាប់ព្រំប្រទល់ភូមិគោកស្រឡៅ ឃុំបារាយណ៍ ស្រុកព្រៃឈរនិងបាធាយអាចាត់ទុកថាបានទទួលលទ្ធផលល្អ ព្រោះយើងបានជួបសម្ភាសន៍ជាមួយអ្នកដឹងឮច្រើន និងបានចុះទៅដល់ទីតាមផ្ទាល់ស្ទើរតែគ្រប់ទីតាំង ។ នេះក៏មកពីយើងមានពេលវេលាគ្រប់គ្រាន់ ដ៏ដូចជាមានការអភិវឌ្ឍទៅលើ

ផ្លូវធ្វើដំណើរពីមុន (១៩៩៧-៩៩) មិនមែនជាផ្លូវពេញលក្ខណៈ ហើយបច្ចុប្បន្នក្លាយជាផ្លូវមួយដ៏ស្អាតក្រោមការស្ថាបនារបស់អង្គការអភិវឌ្ឍន៍ជនបទ ។

ចំពោះបញ្ហាសន្តិសុខវិញ គ្មានអ្វីចោទជាបញ្ហាទេ មានតែការសហការល្អពីបណ្តាប្រជាជនក៏ដូចជាមន្ត្រីសាលាខេត្ត ស្រុក ឃុំ និងភូមិដែរ ។ រាល់ការចុះទៅដល់ទីតាំងមួយៗសុទ្ធតែមានការជូនដំណើរពីមន្ត្រីគ្រប់ជាន់ថ្នាក់ ។

បញ្ហាសំខាន់មួយទៀតសម្រាប់ក្រុមស្រាវជ្រាវយើង គឺយើងមានការស្គាល់ច្រើនពីមន្ត្រីថ្នាក់ឃុំ ស្រុក ខេត្ត នេះក៏ព្រោះតែយើងមានទស្សនាវដ្តីស្វែងរកការពិតដែលទើងតែបានចាប់បដិសន្ធិនៅដើមឆ្នាំ២០០០ ហើយត្រូវ ០ានចែកជូនដោយឥតគិតថ្លៃដល់បណ្តាខេត្ត ស្រុក ឃុំទូទាំងប្រទេសកម្ពុជា ។ ក្រុមស្រាវជ្រាវយើងហាក់មានមោទនៈភាពខាំងនៅពេលដែលប្រាប់ទៅគេថា ធ្វើការបម្រើឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយត្រូវបានទទួលមកវិញនូវភាពរស់រាយ រាក់ទាក់ និងសហករណ៍យ៉ាងអស់ពីចិត្តរវាងមន្ត្រីគ្រប់ជាន់ថ្នាក់ ។

ក្រុមស្រាវជ្រាវយើងសង្ឃឹមថានៅពេលចុះទៅបណ្តាខេត្តផ្សេងៗទៀត ពិតជាបានទទួលបាននូវការសហករណ៍ល្អដូចនៅខេត្តកំពង់ចាមដែរ ។

ចំពោះសាក្សីដែលបានដឹងរឿងរ៉ាវនាសម័យខ្មែរក្រហម សុទ្ធតែបានផ្តល់នូវចម្លើយយ៉ាងស្មោះត្រង់ដល់ក្រុមយើង ។